# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Mar-2011, 09:33
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សារណាបឋមទាក់ទងនឹងអង្គហេតុដែលមិនមានការតវ៉ា

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Göran SLUITER
Annebrecht VOSSENBERG

Alejandra CHAPA (កម្មសិក្សាការីច្បាប់)

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

# សារណា

១. អនុលោមតាម "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ" របស់អង្គជំនុំជម្រះ[1] មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("មេធាវីការពារក្តី") តទៅនេះសូមដាក់សារណាបឋម ទាំងនេះទាក់ទងនឹងអង្គហេតុដែលមិនមានការតវ៉ា ។

២. នៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១១ ការិយាល័យសហព្រះរាជអាជ្ញា ("កសព") បានអញ្ជើញមេធាវីការពារក្តីឲ្យ "ស្វែងរកការណែនាំស្តីពីថា តើកូនក្តីនឹងមិនជំទាស់ទៅនឹងការរកឃើញអំពីអង្គហេតុណាមួយដែលមាននៅទំព័រ ១៣ ដល់ ៣២៣ នៃដីកាដំណោះស្រាយ មានចំណងជើងថា "ជំពូក ១ ការកត់សម្គាល់ឃើញអំពីអង្គហេតុ" និងនៅក្នុងទំព័រ ៣៩០ ដល់ ៣៩៦ មានចំណងជើងថា "ជំពូក ៤ ព័ត៌មាន និងបុគ្គលិកលក្ខណៈ"[2]។ ឆ្លើយតបទៅនឹងការអញ្ជើញនេះ និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយជនជាប់ចោទ មេធាវីការពារក្តីជម្រាបទៅ កសព ថានៅដំណាក់កាលនេះ មេធាវីការពារក្តីមិនអាចយល់ស្របជាមួយសហព្រះរាជអាជ្ញា ទាក់ទងនឹង "អង្គហេតុ"ណាមួយដែលត្រូវបានចោទប្រកាន់យ៉ាងជាក់លាក់នៅក្នុងដីកាដំណោះស្រាយបានទេ ។

---

[1] សូមមើលឯកសារ E-9 "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ" ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១១ ERN 00635754–00635759 នៅកថាខណ្ឌទី៩ ("សហព្រះរាជអាជ្ញា និងក្រុមការពារក្តីនីមួយៗត្រូវដាក់បញ្ជីរួមគ្នានូវអង្គហេតុដែលមិនជំទាស់របស់ពួកគេ ស្របតាមវិធាន ៨០(៣)(គ) មិនឲ្យលើសពីថ្ងៃ២៥ ខែមីនា ឆ្នាំ២០១១ ។ ភាគីនីមួយៗត្រូវបញ្ជាក់ថា តើអង្គហេតុដែលព្រមព្រៀងទាំងនេះនឹងមានការប៉ះពាល់បញ្ជីសាក្សី និងអ្នកជំនាញដែលបានស្នើសុំនីមួយៗដែរឬទេ និងថាតើសាក្សី ឬអ្នកជំនាញដែលបានស្នើសុំណាខ្លះត្រូវបានដកចេញពីបញ្ជី") ។ ដូចខាងលើ នៅកថាខណ្ឌទី ១០ ("សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីត្រូវបន្តសហការគ្នាជាប្រចាំ និងត្រូវរាយការណ៍មកអង្គជំនុំជម្រះសាលាដំបូងឲ្យបានឆាប់រហ័សអំពីអង្គហេតុណាមួយ ឬ បញ្ហាភស្តុតាងដែលភាគី ដែលក្រោយមកខ្លួនបានទទួលស្គាល់ថាជាអង្គហេតុមិនត្រូវបានជំទាស់ ។

[2] អនុស្សរណៈរបស់ កសព ផ្ញើមកមេធាវីការពារក្តី ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ កម្មវត្ថុ: ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ជីរួមគ្នានៃអង្គហេតុដែលមិនជំទាស់" ។ សូមមើលផងដែរឯកសារ **D-427** "ដីកាដំណោះស្រាយ" ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ERN 00604508-00605246។

៣. អាស្រ័យលើមូលហេតុដែលបានបញ្ជាក់រួចមកហើយ[3] មេធាវីការពារក្តីសូមរក្សាសិទ្ធិរបស់ខ្លួនដើម្បីបំពេញបន្ថែម និង/ឬក៏បើមិនដូច្នេះទេ កែសម្រួលសារណាទាំងនេះ *នៅពេលណាក៏ដោយ* តាមការណែនាំបន្ថែមពីជនជាប់ចោទ។ លើសពីនេះទៅទៀត មេធាវីការពារក្តីសូមអះអាងជាថ្មីម្តងទៀតថា ខ្លួនបានដាក់អញ្ញត្រកម្មទាក់ទងនឹងនីត្យានុកូលភាពនៃវិធានផ្ទៃក្នុងនៅអវតក ("វិធានផ្ទៃក្នុង") ជាពិសេសវិធាន ៨០ (៣) (ង)[4]។ មេធាវីការពារក្តីបានអះអាងថា កាតព្វកិច្ចដាក់ដោយវិធាននោះ គឺរំលោភដល់សិទ្ធិនៅស្ងៀម និងការសន្មតជាមុនថា គ្មានទោសរបស់ជនជាប់ចោទ និងបន្ទុកទាំងស្រុង និងដោយគ្មានលក្ខខណ្ឌរបស់ កសព ក្នុងការបង្ហាញភស្តុតាងប្រឆាំងនឹងគាត់[5]។

៤. នៅក្នុងករណីណាក៏ដោយ មេធាវីការពារក្តីដាក់សារណាទាំងនេះដោយភាពស្មោះត្រង់ ហើយប្រកាន់គោលជំហរថាគ្រប់សម្ភារៈទាំងអស់ដែលបានដាក់ រហូតមកដល់ពេលនេះ គឺស្របទៅនឹងកាតព្វកិច្ចជាធរមាននៅក្រោមច្បាប់កម្ពុជា។ មេធាវីការពារក្តីក៏សូមរក្សាសិទ្ធិរបស់ខ្លួនបន្តជំទាស់ទៅនឹងវិធាន ឬដីកាសម្រេចណាក៏ដោយដែលប្រាសចាកពីនីតិវិធីជាតិដែលបានបង្កើតឡើងនេះ។

៥. នៅពេលបច្ចុប្បន្ននេះ មេធាវីការពារក្តីកំពុងទទួលបានការណែនាំបន្ថែមពី នួន ជា ទាក់ទងនឹងអង្គហេតុមួយចំនួនដែលគាត់អាចនឹងមិនជំទាស់នៅក្នុងសវនាការ។ ដូច្នេះ មេធាវីការពារក្តីនឹងដាក់សំណើបែបនេះទៅកាន់ កសព ឲ្យបានទាន់ពេលវេលា និងជូនដំណឹងដល់អង្គជំនុំជម្រះ

---

[3] សូមមើលឯកសារ No E-9/4/4, (នួន ជា) "បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ និងសាក្សី", ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ ERN 00644417–00644423, ("បញ្ជីឈ្មោះសាក្សីរបស់មេធាវីការពារក្តី"), កថាខណ្ឌទី២។

[4] សូមមើលឯកសារ No E-51/3, , (នួន ជា) "អញ្ញត្រកម្មបញ្ជូលគ្នា", ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ ERN 00648279–00648310, កថាខណ្ឌទី៦៦ ដល់៧២ និងឧបសម្ព័ន្ធ ក។

[5] សូមមើលឯកសារ **E-51/3.2** , (នួន ជា) "ឧបសម្ព័ន ក ភាពមិនស៊ីសង្វាក់គ្នារវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ERN 00643795–00643798( ឧបសម្ព័ន ភ្ជាប់អញ្ញត្រកម្មរួមរបស់ នួន ជា។

សាលាដំបូង និងភាគីដទៃទៀត។

សហមេធាវីការពារក្តីលោក **នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE